# ណ

ណ ព្យញ្ជនៈទី៥ ក្នុងវគ្គទី ៣ ជាវគ្គន្តៈ, ជាសកក្ខរៈ-នាសិកក្ខរៈ: មានសំឡេងកើតក្នុងក្បាលនិងច្រមុះ, អាចតម្រួតលើព្យញ្ជនៈ ៤ ក្នុងវគ្គរបស់ខ្លួន និងលើខ្លួនឯងផង គឺ តម្រួតលើ ដ, ឋ, ឌ, ឍ និង ណ ខ្លួនឯងក៏បាន ដូចជា កណ្ឌាល, សណ្ឋាន, បណ្ឌិត; តម្រួតលើ ឍ ឃើញមានតែ ឥណ្ឍ «ព្រះឥន្ទ» មួយប៉ុណ្ណោះ, បណ្ណាការ, បណ្ណាល័យ ។ល។ សម្រាប់ភាសាសំស្ក្រឹតនិងបាលី, ជាឃោសៈ; សម្រាប់ភាសាខ្មែរ, ជាឃោសៈ ក៏មាន ដូចជា ធរណី, បវរណី ឬ ប្រវតណី (-នី)... ។ ជាអឃោសៈក៏មាន ស្មើនឹងតួ ន-អស់, ដូចជា ទៅណា ?, ណាយចិត្ត, ចំណី, ប្រណី ។ល។ ណ នេះអាចតម្រួតលើ ហ ក៏បាន, ជាឃោសៈ (មានសំឡេងក្នុងច្រមុះ), ដូចជា តណ្ហា, វណ្ហិយ; សណ្ហសុខុម «ល្អិតណាស់» ជាដើម ។

ណាតណាយ ឬ តតតយ ន. សូរសព្ទស្រទន់ស្លៀងពិណពាទ្យ ។

ណា សព្វ. ពាក្យជាអនិយតសព្វនាម ប្រាប់សេចក្ដីមិនទាន់ទៀង, មិនទាន់ប្រាកដ ឬមានអាការជាសេចក្ដីសង្ស័យ: ទៅផ្លូវណាក៏បាន; តាមតែអ្នកណាក៏ដោយ; អ្នកណាធ្វើអំពើល្អ នោះល្អក៏ អាក្រក់ក៏, អ្នកនោះនឹងបានទទួលផលនៃអំពើនោះវិញពុំខាន; មកពីណា ? ទៅណា ? អ្នកណាទើបនោះ ?... ។ ណាមួយ ពីមួយ ។ ណាក៏ដោយ ក៏ដោយ ។

ណាំ! ឬ ណាំះ! (ម. ព. ណាំះ!) ។

ណាត់ ១ កិ. និយាយព្រមព្រៀង, មត់ កំណត់វេលានឹងជួបគ្នា: ខ្ញុំបានណាត់នឹងគាត់ថា ឲ្យគាត់មកជួបគ្នានៅផ្លូវអ្នកគង់វេលាព្រឹកនេះឯង ។

ណាត់ ២ ន. ចំនួនផែលប្រាក, ចម្រូក; និយាយចំពោះតែកាំភ្លើងឬកាំជ្រួច: ប្រកាំភ្លើង១ណាត់; បាញ់កាំភ្លើងធំ២១ណាត់ជាប់... ។

ណាមស្រង់ ន. (ស. នាំស្រង ឬ ថៃ. នាំស្រង) ទឹកសម្រាប់ស្រង់ គឺ នាំ ស. «ទឹក», ស្រង់ «ស្រង» (រ. ស.): ថ្វាយណាមស្រង់; ប្រើតាមទំនៀមសម័យនៃអតីតកាល. ហៅតាមសព្ទពិតថា ព្រះឧទក:, ព្រះឧទការោទក (-ទក់), ព្រះស្នានគា (ម. ព. ទាំងនោះ) ។

ណាយ កិ. រសាយចិត្ត, លាកចិត្ត: ណាយចិត្ត, ណាយគំនិត ។ ធឿយណាយ ពិតឿយចិត្ត ណាយគំនិត, ថយចំណង់, ធុញទ្រាន់ ។

ណាស់ និ. ក្រៃពេក, ក្រៃលែង, លើសលុប, ខ្លាំង: ល្អណាស់, អាក្រក់ណាស់, ខូចណាស់ ។ ប្រើជា កិ. វិ. ក៏បាន: ខ្ញុំត្រេកអរណាស់ ដោយបានឃើញអ្នកមកដល់!

ណាស់សា និ. (ព. សា.) ពាក្យសម្រាប់និយាយបន្ថែមសង្កត់លើពាក្យ ណាស់ ឲ្យរឹតតែខ្លាំងឡើងទៀត: ពុំបាក្ខនអ្នកឯណោះ កខិលណាស់ទៅហើយ, តែកំណែកទានក្ខនខ្ញុំឯណេះ ក៏ក៏តែខូចណាស់សាទៅទៀត ។ ប្រើនិយាយកាត់ខ្លីៗថា: អណាស់សាហើយ, ដូចជាណាស់សាពេកហើយ ។

ណឹងណុង ឬ ណោងណុង ន. សូរសព្ទគងភ្លេងពិណពាទ្យផ្ទៃត្តុច ។

ណិមណុម ឬ ណិមណាំ កិ. ឬ កិ. វិ. ក្រិមក្រុម ដោយអាការយៀនប្រៀន ឬដោយអាការក្រេះក្រុះ: អង្គុយណិមណុម (ម. ព. រណិមរណំ ទៀតផង) ។

ណិល កិ. វិ. ណេង, ពិញ, ពិល: រលីងណិល (ម. ព. ពិញ, ពិល និង រលីង ផង) ។

ណឹង ១ កិ. វិ. ផែលទំនង, ទីងប្រទ្បក: ទីងណឹង, ប្រឡូកណឹង (ម. ព. តឹង ផង) ។

ណឹង ២ ឬ ណឹងៗ ន. សូរសព្ទកណ្ដឹង, រោង ។

ណុង ឬ ណុងៗ ន. សូរសព្ទគង ឬគាំងតូច ។

ណូរី ឬ នូរី ន. ឈ្មោះបក្សីមួយប្រភេទ រូបស្រដៀងនឹងសេកលេច តែមានសម្បុរក្រហម ។

ណេងណុង (ម. ព. ណឹងណុង) ។

ណេះណោះ (-ណុះ) កិ. វិ. ពីនេះពីនោះ, ខាយ-អាយ: និយាយណេះណោះ គឺនិយាយពីនេះខ្លះ ពីនោះខ្លះ ឬនិយាយពិណាលពីខាងនាយខ្លះ ពីខាងអាយខ្លះផ្សេងៗ តែពុំជាការ ។

ណែ កិ. ល្មម, ល្មមល្អ, ពល្មល់: ណែផ្លូវ, ណែទិស, ណែឲ្យយល់ក្ដីពីការធ្វើ ។

ណែកណក កិ. ក្ដិចក្ដុក, គុកគីក (ព. សា. មិនសូវប្រើ) ។ ន. គោះប្រាប់ផ្ទាក់ភ្លេងពិណពាទ្យ (មិនសូវប្រើ) ។

**ណែងណង** *ន.* កំណាត់ឈើឬឫស្សី ចងបញ្ឆោត បន្តុលជិត ភ្ជាប់នៅកសត្វចតុប្បាទ មានគោ, សេះ, ដែលជាដើម ដើម្បីឲ្យទើសទាល់ដល់ជើងមុខមិនឲ្យលោតបាន : *ចងណែង-ណង, ដាក់ណែងណង* ។

**ណែងណោង** *គុ. វិ.* ដែលចង្អៀតបញ្ឆោតតែតោង ពីក្រោម, រណែងរណោង : *ព្យួរណែងណោង* ។

**ណែណន** *គុ.* (*ស. រេខ្ខន* ម. ថ. *ណែណន*) ដែលបិតជិត, ភ្ជាប់ខ្ជួន, យឺនយូរ, ប្រាកដប្រជា, ចំណាប់ចំនួន (មិនសូវប្រើ) ។

**ណែន ១** *គុ.* តឹង, រឹង, ចង្អៀត, ហាប់ : *ភ្ញៀវអង្គុយណែនតឹងពេក* ។

**ណែន ២** *ន.* ឈ្មោះប្រាក់ដុំមួយបែបរបស់ពួកអ្នកស្រុកសៀមនិងស្រុកប្រ៉ក, ធ្ងន់ ១០ តម្លឹង ឬ ១០ តម្លឹង ២ ជី, តាមជាប្រាក់កាយចំនួន ១៥ រៀល ឬ ១៦ រៀលដោយចុះឡើងតាមកាលតាមសម័យ; សព្វថ្ងៃនេះលើកលែងបាត់ហើយ ។

**ណែនណាន់** *គុ. វិ.* ឬ *គុ.* កកកុញ, ចុកចិត : *ឈើណែនណាន់; មនុស្សច្រើនណែនណាន់ ។ ណែន-ណាន់តាន់តាប់* គឺណែនណាន់ភ្ជាន់ភ្ជាប់ពេញពាស ។

**ណែនាំ** *កិ.* ប្រាប់ទំនង ប្រាប់មាយា ឲ្យយល់ឲ្យភ្លឺ, ដាស់ឲ្យធ្វើដោយពន្យល់បង្ហើរ : *សូមជួយណែនាំខ្ញុំផង* ។

**ណែម** *ន.* (យ.) ឈ្មោះម្ហូបគោកមួយប្រភេទ ធ្វើដោយស្បែកជ្រូកឬលាយសាច់ចិញ្ច្រាំមានស្លឹកខ្ទឹមលាយឬស្លឹក ក្ទុកស្រុក, ស្លឹកចាពុ ខ្ចប់ជាមួយគ្នា ទុកឲ្យឡើងជាយក្រាផ្អូរ បន្តិចៗ ។

**ណែលណោល** *គុ. វិ.* ឬ *គុ.* ដែលតោល (ម. ព. តោះ) ។

**ណែរ** *ន.* (យ.) ឈ្មោះកងដៃមួយប្រភេទ : *កងណែរ, ពាក់កងណែរ* ។

**ណៃខ្លួន** *គុ.* (*ស. និម្មល* ម. ថ. *និម្មល* ឬ *និម្មលិម*) ល្អមល្អៃ, ល្អក្លៃ, ទន់ភ្លន់, សមរម្យ, សមសួន : *ដំណើរណៃខ្លួន, ឫកពាណៃខ្លួន* ។

**ណៃវ៉ា** *ន.* ឈ្មោះទូកមួយប្រភេទ : *ទូកណៃ-វ៉ា; ណៃវ៉ាជាទូកមានប្រយោជន៍ជំសំខាន់ណាស់ ព្រោះប្រើការបានច្រើនមុខច្រើនយ៉ាងជាទូកចាំយាំ ចាយកើត ក្នុងប្រទេសកម្ពុជាយើង* ។

**ណាំង** ឬ **ហ្នាំង** *ន.* (*ស. ហ្នង* "ស្បែក") ស្បែកទាក់ជារូបតំណាងតួផ្សេងៗ សម្រាប់ប្រើក្នុងល្បែងរបាំ កាន់លើកទុះស្រមោលក្នុងស្បែកស ឲ្យឃើញច្បាស់ តាមដំណើររឿងដែលអ្នករបាំកំពុងពោលកំពុងថ្លែង : *លេងណាំង, ទៅមើលណាំង* ។ ហៅតាមពាក្យខ្មែរយើងថា *រាំស្បែក* ។



**ណ៎ះ!, ណ៎ា!, ណ៎ោះ! ឬ ហ្ន៎ះ!, ហ្ន៎ា!** *និ.* ពាក្យនិបាត មានសំឡេងឡើងខ្ពស់ស្រួច ឬស្រទន់ សម្រាប់និយាយបញ្ជាក់សេចក្តីឲ្យប្រាកដ មានអាការៈហាក់ដូចជាចួល ឬ សួរថែមថា *"មិនមែនឬ ?, មិនមែនដូច្នោះឬ ?"*; និយាយទៅរកបានចំពោះតែមនុស្សអ្នកតូចទាបជាង ឬដែលស្និទ្ធ-ស្នាល, ដែលស្មើគ្នា : *នែ, ទៅកុំខានណ៎ះ!; ប្រយ័ត្នណ៎ះ!; កុំភ្លេចណ៎ះ!; សុំឲ្យកូនមែនបានជាសះ-ស្បើយតាំងពីថ្ងៃនេះទៅណ៎ះនាងណា!...* ។

**ណ្ហើយ** *និ.* កុំឡើយ, កុំបាច់ឡើយ ។ ពាក្យនិបាតជា បដិសេធន៍សម្រាប់និយាយឃាត់ឲ្យឈប់ត្រឹមប៉ុណ្ណោះ : *ណ្ហើយកុំយក!; ណ្ហើយកុំនិយាយ!...* ។ ប្រាប់សេចក្តីថា ល្មមហើយ ក៏បាន : *ណ្ហើយ, យើងឈប់នៅនេះចុះ!; ណ្ហើយ, ខ្ញុំជម្រាបលាអ្នកតាំងពីអស់គ្នាហើយ!; ណ្ហើយ, មិនលាក់យស់នេះហើយណ៎ះ!*

**ណ្ហើយចុះ** *និ.* ប៉ុណ្ណឹងចុះ, មិនជាអ្វីចុះ, កុំបាច់ចុះ, មិនថ្វីទេ : *ណ្ហើយចុះ ចាំខ្ញុំទៅ!; ណ្ហើយ, ប៉ុណ្ណឹងចុះ!; ណ្ហើយ, កុំឲ្យទៀត, ប៉ុណ្ណឹងល្មមហើយ!*